# សក្ដានុពលនៃមរតកធារាសាស្ត្របុរាណ
# ក្នុងឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

ដោយ : បណ្ឌិត ផុន កសិកា[1]

លោក ឡេង វិទូ[2] និង កញ្ញា តាកេត ស័កដា[3]

## សេចក្ដីផ្ដើម

ទីតាំងឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ស្ថិតក្នុងតំបន់ទំនាប ចន្លោះទន្លេមេគង្គ និង ទន្លេតូចៗ។



ផែនទីឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

កិច្ចសហការស្រាវជ្រាវរវាងរាជបណ្ឌិត្យសភាកម្ពុជា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរដែនដីឃុំបារាយណ៍ និង សាកលវិទ្យាល័យហ្វ៊ីនឌ័រ ប្រទេសអូស្ត្រាលី បានរកឃើញភស្តុតាងប្រាសាទ គ្រឹះប្រាសាទ ឡដុតកុលាលភាជន៍ ទួលមនុស្សរស់នៅ បារាយណ៍ ត្រពាំង ព្រមទាំងប្រព័ន្ធធារាសាស្ត្រមួយចំនួនទៀត ដែលបង្ហាញថា ឃុំបារាយណ៍គឺជាទីតាំងមនុស្សរស់នៅ តាំងពីសម័យបុរេប្រវត្តិសាស្ត្រ សម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ និងបន្តរហូតដល់បច្ចុប្បន្ននេះ[4]។

---

[1] បណ្ឌិត ផុន កសិកា ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា

[2] លោក ឡេង វិទូ ប្រធានស្ដីទីនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

[3] កញ្ញា តាកេត ស័កដា វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា

[4] នាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ វិទ្យាស្ថានស្រាវជ្រាវជាតិណាប៉ា ដើម្បីសម្បត្តិវប្បធម៌ សាកលវិទ្យាល័យហ្វ៊ីនដឺ «របាយការណ៍បឋម ស្ដីពី គម្រោងស្រាវជ្រាវរាជធានីសម័យកណ្ដាល និង បុរាណដ្ឋាន» ឆ្នាំ២០២៣។



រូបលេខ១ : ប្រាសាទព្រះធាតុបាពយណ៍

អ្នកស្រាវជ្រាវក៏បានរកឃើញកស្តុតាងដូចជាទំនប់បុរាណ ដែលជាទីតាំងស្តុកទឹក អាចបញ្ជាក់ថាទីតាំងនេះគឺជាមជ្ឈមណ្ឌលផលិតកម្មស្រូវដ៏ធំមួយដែរក្នុងប្រទេសកម្ពុជា។

ការធ្វើកសិកម្មស្រូវនៅទីនោះពឹងផ្អែកលើប្រព័ន្ធធារាសាស្ត្រមួយបែប ដែលអ្នកស្រុកថា «ចន្ទក់» «មេទឹក» «ទំនប់» ឬ «វង់កុង»[5]។

ចន្ទក់ ឬ មេទឹកសំដៅលើសំណង់ទំនប់ទឹកមានរាង២ជ្រុង ឬ ៣ជ្រុង សង់ឡើង ឬ លើកភ្ជាប់គ្នានៅចំណុចណាមួយ ដើម្បីឱ្យទឹកដក់នៅត្រង់ចំណុចភ្ជាប់គ្នានោះ[6]។

អត្ថបទនេះនឹងបង្ហាញអំពីកស្តុតាងមេទឹកមួយចំនួនដែលជាប្រព័ន្ធធារាសាស្ត្របន្សល់ពីសម័យបុរាណ នៅរក្សារូបរាងដល់បច្ចុប្បន្ន និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រទាំងអស់នោះរបស់ប្រជាពលរដ្ឋក្នុងឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ការប្រើប្រាស់ និង អភិវឌ្ឍប្រព័ន្ធធារាសាស្ត្រពីបុរាណបានផ្តល់ប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ មានដូចជាទឹក អាហារ (ត្រី សាច់ បន្លែ) និងការថែរក្សាជីវចម្រុះសម្រាប់តំបន់នោះ។

ការសិក្សាស្រាវជ្រាវពឹងផ្អែកលើការចុះសិក្សាដល់ទីតាំងស្ថានីយដោយប្រើវិធីសាស្ត្របុរាណវត្ថុវិទ្យាខ្លះដើម្បីប្រមូលទិន្នន័យ រួមផ្សំជាមួយនឹងកិច្ចសម្ភាសជាមួយអាជ្ញាធរដែនដីឃុំបាពយណ៍ និងចាស់ទុំដែលរស់នៅ និងអាស្រ័យផលពីប្រព័ន្ធធារាសាស្ត្រទាំងនោះ។ ការសិក្សានេះពឹងផ្អែកលើរូបភាពលើអាកាសនៃGoogle ដើម្បីជួយបង្ហាញរូបភាពពីលើអាកាសនៃទីតាំងនីមួយៗ និង អាចជួយផ្តល់ទិន្នន័យទំហំនៃមេទឹកទាំងនោះ។

[5] សូមអាន ផុន កសិកា, ឡេង វិទូ, តាកេត ស័កដា, សួ ប៉ុណ្ណារ៉ាត់ «ប្រព័ន្ធធារាសាស្ត្រនៅតំបន់ខាងកើតបន្ទាយលង្វែក ក្នុងឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល» ក្នុង កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ១(២) ខែវិច្ឆិកា ឆ្នាំ២០២២ ទំព័រ១-២១។

[6] សូមអាន Nhim, Sotheavin. ( 2016 ). Factors that Led to Change of the Khmer Capitals from the 15ht to 17th Century, Sophia University, Tokyo.



ផែនទីបង្ហាញពីមេទឹកនិងស្ថានីយបុរាណក្នុងឃុំបារាយណ៍

## ១. របកគំហើញមេទឹក

ឃុំបារាយណ៍មានភូមិចំនួន៤ : ភូមិស្បាអំពិល ភូមិបន្ទាយ ភូមិស្បាបឹងវែង និងភូមិកំផ្លាក់ ដែលមានភស្តុតាងស្ថានីយបុរាណ។ ក្នុងអត្ថបទនេះ យើងសូមបង្ហាញតែភស្តុតាងបុរាណវត្ថុវិទ្យា មេទឹក ឬ ចន្ទក់ នៅតាមភូមិនីមួយៗ។

### ១.១-ភូមិស្បាអំពិល

នៅក្នុងភូមិស្បាអំពិលមានមេទឹកដែលនៅតំបន់នេះគេហៅថាទំនប់សម្រាប់ទប់ទឹកផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋមាន៤ គឺបឹងកក់ដែលជាប្រភពទឹកធំ បឹងទន់ស បឹងរាំងតូច បឹងឫស្សី[7]។

-**មេទឹកបឹងកក់** ស្ថិតក្នុងភូមិស្បាអំពិលមានប្រវែងជាង២គីឡូម៉ែត្រ និងទំហំ១៥៨ហិកតា។



រូបលេខ២២: មេទឹកបឹងកក់ (រូបភាពពីGoogle Earth)



រូបលេខ២៣ : មេទឹកបឹងកក់ (រូបភាពពីDrone)

**មេទឹកបឹងឫស្សី** ស្ថិតក្នុងភូមិស្បាអំពិល។ តាមការសិក្សាបញ្ជាក់បន្ថែមពីរូបភាព Google Earth បង្ហាញថា មេទឹកបឹងឫស្សីមានបរិមាត្រប្រវែង៧០០០ម៉ែត្រ និងទំហំ២៥០ហិកតា។ មេទឹកបឹងឫស្សីស្ថិតនៅខាងត្បូងមេទឹកបឹងកក់។ នៅចន្លោះមេទឹកទាំងពីរ (មេទឹកបឹងកក់ និង មេទឹកបឹងឫស្សី) គឺជាវាលស្រែដែលអ្នកស្រុកនៅទីនោះហៅថា «ចន្ទក់»។



រូបលេខ២៤ : មេទឹកបឹងឫស្សី (រូបភាពពីGoogle Earth)

[7] សម្ភាសលោក គង់ សុមុនី ជំទប់ទី១ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។



រូបលេខ២៥ : រូបភាពវាលស្រែនៅចន្លោះមេទឹកបឹងកក់ និង មេទឹកបឹងឫស្សី

**មេទឹកបឹងរាំង** ស្ថិតនៅជាប់នឹងមេទឹកបឹងឫស្សីដែរ។ មេទឹកនេះមានទំហំតូចនិង ស្ទើររាំងអស់ទឹកទៅហើយ។ មានទំហំ២៥ហិកតា។



រូបលេខ២៦ : មេទឹកបឹងរាំង (រូបភាពពីGoogle Earth)

**មេទឹកនន់ស** ស្ថិតនៅខាងលិចមេទឹកបឹងរាំង។ មេទឹកនេះធំមានទំហំរហូតដល់១១៤ ហិកតា។



រូបលេខ២៧ : មេទឹកនន់ស (រូបភាពពីGoogle Earth)

## ១.២-ភូមិស្សាបឹងវែង

-**ទំនប់ថ្មី** មាននិយាមការ (X: 521416.6, Y: 1309801.5) ស្ថិតនៅក្នុងភូមិស្សាបឹងវែង ឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ទំនប់ថ្មីនេះមានទួលព័ទ្ធជុំវិញ ដូចជាទួលឡោក ទួលកាន់ស្នេហ៍ ទួលតាពេង ទួលកណ្ដាល ទួលថ្នឹង និងទួលពោធិ៍។ ចន្លោះមេទឹកគឺពីទួលឡោក ទៅកាន់ទួលថ្នឹង។ ទំនប់នេះ គេតែងទប់ទឹកទុក ដល់ពេលដែលត្រូវការទឹកទើបគេបើកបង្ហូរទឹកបញ្ចូលក្នុងស្រែដែលស្ថិតនៅភាគខាងកើត ត្បូង និងខាងលិច។ យើងបានពិនិត្យមើលទួលកាន់ស្នេហ៍ឃើញមានបំណែកកុលាលភាជន៍សម័យអង្គរ (គួលែន និងជើងឯក) បំណែកកុលាលភាជន៍ចិន និងបំណែកកុលាលភាជន៍សម័យថ្មី។

នៅតាមទំនប់ថ្មីនេះ មានទួលមនុស្សរស់នៅពីសម័យបុរាណ ដែលតាមរយៈបំណែកកុលាលភាជន៍ យើងអាចសន្និដ្ឋានជាបឋមថា ទួលបុរាណនេះមានមនុស្សរស់នៅតាំងពីសម័យមុនអង្គរ រហូតល់ដល់សម័យអង្គរ និងបន្តដល់សម័យកណ្ដាលទៀត (សន្និដ្ឋានយោងលើកស្ដុតាងបំណែកកុលាលភាជន៍រកឃើញនៅលើទួលមនុស្សរស់នៅ)។ ចំណែកទំនប់វិញ ក្រុមស្រាវជ្រាវ

មិនអាចសន្និដ្ឋានអំពីកាលបរិច្ឆេទនៃការសាងសង់បាន។

ការសិក្សាផ្ទៃខាងលើ គឺជាវិធីសាស្ត្រដំណាក់កាលដំបូង សម្រាប់ទាញសន្និដ្ឋានថាតើ ទំនប់មានអាយុកាលចាស់ជាងទួលមនុស្សរស់នៅ ឬ ទំនប់មានអាយុកាលក្មេងជាងទួលមនុស្សរស់នៅ?



រូបលេខ៨ : មេទឹកទំនប់ថ្មី (រូបភាពពីGoogle Earth)



រូបលេខ៩ : ទិដ្ឋភាពផ្នែកខាងក្នុងមេទឹកទំនប់ថ្មី



រូបលេខ១០ : រូបភាពពីលើអាកាសនៃមេទឹកទំនប់ថ្មី




រូបលេខ១១ : រូបភាពទំនប់ថ្មីបង្ហាញពីវត្តមានទួលមនុស្សរស់នៅស្ថិតជាប់ខាងក្រៅទំនប់មេទឹក

**-មេទឹកចន្ទក់ចាស់**

ស្ថិតក្នុងភូមិស្បាបឹងវែង ឃុំបាពយណ៍។

ចន្ទក់ចាស់ (គឺជាប្រព័ន្ធទឹកសម័យបុរាណមួយ) ស្ថិតក្នុងភូមិស្បាបឹងវែង ឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ចន្ទក់ចាស់រាងកោងដូចដងធ្នូ មានប្រវែង ២០០០ម៉ែត្រ ស្ថិតនៅខាងត្បូងចម្ងាយប្រមាណ៧០០ម៉ែត្រពីទួលកានាគ ដែលជាទួលបុរាណមួយ និងជាទួលដែលអ្នកស្រាវជ្រាវកំពុងធ្វើកំណាយស្រាវជ្រាវ។

នៅឆ្នាំ២០០៤ រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីបានឧបត្ថម្ភការស្តាប្រព័ន្ធទឹកចន្ទក់ចាស់នេះឡើងវិញ សម្រាប់ប្រជាកសិកររស់នៅក្នុងភូមិស្បាបឹងវែងធ្វើស្រែប្រាំងបាន។ ជំនួយឧបត្ថម្ភការស្តារប្រព័ន្ធទឹករបស់រដ្ឋាភិបាលប្រទេសអូស្ត្រាលីនៅឆ្នាំ២០០៤ ក៏បានធ្វើនៅសន្ទក់ថ្មី ឬ ទំនប់ថ្មី ដែលក្រុមស្រាវជ្រាវក៏បានធ្វើកំណាយស្រាវជ្រាវដែរ។



រូបលេខ១២ : មេទឹកចន្ទក់ចាស់ (រូបភាពពីDrone)



រូបលេខ១៣ : មេទឹកចន្ទក់ចាស់ (រូបភាពពីGoogle Earth)



រូបលេខ១៤ : សំណង់ទ្វារទឹកសង់នៅចន្ទក់ចាស់ នៅឆ្នាំ២០០២ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី

### ១.៣-ភូមិកំផ្លាក់

**-មេទឹកបាយដេ** ស្ថិតក្នុងភូមិបន្ទាយ មានសណ្ឋានស្រដៀងនឹងចន្ទក់ចាស់ដែរ។



រូបលេខ១៥ : មេទឹកបាយដេ (រូបភាពពីDrone)



រូបលេខ១៦ : មេទឹកបាយដេ (រូបភាពពីGoogle Earth)

**-បឹងវាង** មាននិយាមការ (X: 517819 ,Y: 1308381) ស្ថិតនៅជាប់នឹងភូមិកំផ្លាក់ ឃុំបារាយណ៍ ឃុំព្រែកដំបូក ឃុំផ្ទះកណ្ដាល ឃុំប្រាំយ៉ាម និងឃុំព្រែកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ប៉ុន្តែឃុំដែលមានដីអាចធ្វើកសិកម្មជាប់នឹងបឹងវាង មានតែបីឃុំទេ គឺឃុំប្រាំយ៉ាម ឃុំផ្ទះកណ្ដាល និងឃុំបារាយណ៍។ បឹងវាងមានស្ទឹងមួយឈ្មោះស្ទឹងស្ពាន ជាប់គ្នានឹងបឹងបាត ឬ បឹងស្ពាន ហើយភ្ជាប់ទៅនឹងដៃព្រែកដំបូក ភ្ជាប់ទៅនឹងទន្លេកំពប ដែលបែកចេញពីទន្លេមេគង្គ។ នៅម្ខាងទៀតនៃបឹងវាង មានព្រែកចំប៉ា ដែលភ្ជាប់នឹងទន្លេតូច ជាប់នឹងព្រំប្រទល់ស្រុកស្រីសន្ធរ និង ស្រុកពារាំង ខេត្តព្រៃវែង។ តាមរយៈការសម្ភាសន៍ជាមួយអ្នកស្រុករស់

នៅឃុំបារយណ៍បានប្រាប់ឱ្យដឹងថា ពីមុនមកបឹងនេះមិនដែលរីងនោះទេ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយនេះបឹងធ្លាប់រីងពីរដងមកហើយ ដោយសារមានអ្នកទប់ទឹកសម្រាប់ធ្វើស្រែ និងយកទឹកលក់។ ទោះបីជាបឹងរីងមែន តែមិនមានអ្នកធ្លាប់ស្ដារបឹងនេះឡើយ។



រូបលេខ១៧ : ទិដ្ឋភាពបឹងវាមមើលពីលើអាកាស តាមរយៈរូបថតដ្រូន



រូបលេខ១៨ : សកម្មភាពសួរព័ត៌មានអំពីបឹងវាម ពីអ្នកភូមិ

### ១.៤-ភូមិបន្ទាយ

**-ចន្លក់លិច** ស្ថិតក្នុងភូមិបន្ទាយនៅ មានខ្ទង់ទំនប់ច្បាស់។




រូបលេខ១៩ : មេទឹកលិចស្ថិតក្នុងភូមិបន្ទាយ

## ២. ស្ថានភាពប្រព័ន្ធធារាសាស្ត្រ

ជាទូទៅ មេទឹកទាំងអស់នៅក្នុងឃុំបារាយណ៍ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ជាកន្ទ្វែងស្តុកទឹកសម្រាប់ស្រោចស្រប់ស្រែប្រាំង បន្ទាប់ពីទឹកស្រកពីស្រែដែលលិចក្នុងរដូវវស្សា។ ដោយសារអាយុកាលនៃមេទឹក និងការប្រើប្រាស់ជាច្រើនឆ្នាំមកហើយ ទំនប់មេទឹកទទួលរងការសឹករិច ដាច់ធ្លាយ ព្រមទាំងកកស្ទះ ដែលតម្រូវឱ្យអភិវឌ្ឍដោយសហគមន៍ក្នុងភូមិរៀងៗខ្លួន។

តាមរយៈលោក គង់ សុខមុនី ដែលជាជំទប់ទី១ឃុំបារាយណ៍ បានប្រាប់ឱ្យដឹងថា «មានមេទំនប់ដែរ តែមិនមានទំនប់ច្បាស់លាស់ គឺគ្រាន់តែថាក្នុងមេទំនប់ទាំងអស់ ប្រជាពលរដ្ឋទាំងអស់ឱ្យសិទ្ធទៅលើមេទំនប់[8]។ នៅពេលមួយ ភូមិជ្រើសរើសអ្នកស្ម័គ្រចិត្ត ដែលអាចដើរពិនិត្យមើលទំនប់ដែលដាច់ ឬខូច។ កាលនោះដែរ អ្នកភូមិ

[8] អ្នកស្រុកហៅថា «មេទំនប់» គឺសំដៅលើអ្នកដែលដេញថ្លៃបានក្នុងការគ្រប់គ្រងថែទាំមេទឹក។

ជួយផ្ដល់ដល់អ្នកមើលថែការពារទំនប់មេទឹក ជាស្រូវ។ អស់រយៈពេលយូរទៅ ស្ថានភាពពិបាកខាងលទ្ធភាពឧបត្ថម្ភរបស់អ្នកស្រុក ក្រុមគណៈកម្មការ ក្រុមអាចារ្យភូមិព្រមទាំងប្រជាពលរដ្ឋបានសម្រេចជ្រើសរើសរកអ្នកដែលមានសិទ្ធក្នុងការដេញថ្លៃ ហើយក៏ព្រមព្រៀងគ្នា មានការកិច្ចព្រមព្រៀងរយៈពេលទៅតាមភាពជាក់ស្ដែងនៃទីតាំងមេទឹក។ មេទឹកខ្លះមានកិច្ចព្រមព្រៀងរយៈពេល១១ឆ្នាំ ១២ឆ្នាំ ឬ ១៣ឆ្នាំ»។

គោលបំណងបង្កើតឱ្យមានអ្នកថែរក្សាមេទឹក ដែលគេហៅថា «មេទំនប់» ក្នុងគោលបំណងជួយថែទាំទំនប់ស្តុកទឹកឱ្យបានច្រើន សម្រាប់ផ្គត់ផ្គង់ទឹកដល់ស្រែប្រាំងដែលស្ថិតជាប់នឹងទំនប់។ ពលរដ្ឋបានទទួលផលពីទឹកដែលមេទំនប់បានថែរក្សាទុក ហើយផ្គត់ផ្គង់ គ្រាន់ជូនពួកគាត់ក្នុងពេលរដូវប្រាំង ធ្វើស្រែបានគ្រប់គ្រាន់។

មេទំនប់ដែលទទួលសិទ្ធថែរក្សាទំនប់ត្រូវទទួលភារកិច្ចដូចជា៖ ទី១ ត្រូវការពារទឹក ឱ្យប្រកពទឹកមានកម្រិតគ្រប់គ្រាន់សម្រាប់ពលរដ្ឋដែលមានស្រែប្រាំងនៅខាងក្រៅ ឬ ហៅថា ចន្ទក់ បានទឹកគ្រាប់គ្រាន់ប្រើក្នុងរដូវស្រែប្រាំង។ ទី២ ត្រូវមើលថែរក្សាទំនប់ឱ្យមាំ កុំឱ្យបាក់ កុំឱ្យដាច់ខូច។ ទី៣ ត្រូវថែរក្សាព្រៃសហគមន៍ ដែលរាល់ព្រៃសហគមន៍ត្រូវថែរក្សា ហាមមិនឱ្យនរណាកាប់ ដុត ឬទន្ទ្រានយកទេ។ ទី៤ គាត់បានទទួលផលប្រយោជន៍ជាត្រីវិញ ដោយសារគាត់បានដេញថ្លៃ ផលដែលគាត់ប្រមូលបានគឺត្រីសម្រាប់លក់ចែកជូនប្រជាពលរដ្ឋ។

សម្រាប់អ្នកដែលទទួលបានសិទ្ធជាអ្នកមើលថែរក្សាទំនប់គឺត្រូវទទួលបានការទុកចិត្តពីប្រជាពលរដ្ឋ ទើបគាត់អាចផ្ដល់សិទញធនេះបាន។ លោក ចុង ម៉ៅ បានបង្ហាញថា «ដោយសារពួកគាត់មើលឃើញថា ខ្ញុំមានសមត្ថភាពគ្រប់គ្រង ពួកគាត់ក៏ទុកចិត្តមកលើពួកខ្ញុំ។ ពួកគាត់ក៏បានប្រគល់ទំនប់ឱ្យខ្ញុំកាន់កាប់ ដើម្បីស្តុកទឹកទុកដើម្បីឱ្យប្រជាពលរដ្ឋប្រើប្រាស់នៅចន្ទកបឹងកក់ខាងកើត។ ពួកគាត់ឱ្យខ្ញុំកាន់កាប់ទំនប់ដោយត្រូវធ្វើទំនប់ខ្នងលើ៥ម៉ែត្រ ជើងប្រហែល៨ម៉ែត្រ កម្ពស់២ម៉ែត្រ ហើយឱ្យខ្ញុំកាន់កាប់រុន ត្រី និងថែរក្សាព្រៃសម្រាប់កូនចៅទៅថ្ងៃក្រោយ[10]។

[9] សម្ភាសលោក គង់ សុមុនី ជំទប់ទី១ ឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

[10] សម្ភាសលោក ចុង ម៉ៅ មេទំនប់ រស់នៅភូមិស្បាអំពិល ឃុំបាពយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។



រូបលេខ២០ : លោក ចុង ម៉ៅ គឺជាមេទំនប់ ដែលទទួលសិទ្ធក្នុងការថែទាំមេទឹកបឹងកក់

មេទឹកក្នុងភូមិផ្សេងៗទៀតក្នុងឃុំបារាយណ៍ ដូចជាមេទឹកចន្ទក់ចាស់, មេទឹកបាយដេ និង មេទឹកទំនប់ថ្មី ដែលសុទ្ធតែជាមេទឹកធំៗអាចស្តុកទឹកសម្រាប់ផ្គត់ផ្គង់ស្រូវប្រាំងបានច្រើនហិចតា ក៏ប៉ុន្តែមេទឹក ឬ ទំនប់ទាំងនោះមិនមានការអភិវឌ្ឍដូចមេទឹកបឹងកក់ទេ។

## ៣. អត្ថប្រយោជន៍នៃមេទឹក

គោលបំណងនៃការសាងសង់មេទឹកជាចម្បងគឺប្រមូលទឹក ឬ ស្តាក់ទឹកនៅក្នុងមេទឹកសម្រាប់ស្រោចស្រប់ដំណាំស្រូវក្នុងរដូវប្រាំង។ ជាធម្មតា ក្នុង១ហិកតា កសិករដែលមានដីនៅជាប់មេទឹកអាចធ្វើស្រែបានទិន្នផល៥តោនក្នុងមួយហិកតា។ ប្រសិនបើល្អខ្លាំងគេអាចទទួលបាន៦តោនក្នុងមួយហិកតា[11]។



រូបលេខ២១ : ផលស្រូវដែលត្រៀមលក់ចេញ



រូបលេខ២២ : សកម្មភាពប្រមូលផលស្រូវរបស់ប្រជាពលរដ្ឋក្នុងឃុំបារាយណ៍

ក្រៅពីនេះ មេទឹកក៏អាចផ្តល់ធនធានអាហារដូចជាត្រី សត្វផ្សេងៗទៀត។ លោក ចុង ម៉ៅ បានបង្ហាញបន្ថែមទៀតថា «មានត្រីផ្ទក់ ត្រីអណ្តែង ត្រីក្រាញ់ ត្រីកំផ្លៀញ ...មានត្រីឆ្ដូញដែរ តែមានតិច»[12]។



រូបលេខ២៣ : ត្រីប្រមូលពីមេទឹកបឹងកក់

[11] សម្ភាសលោក ណោ ណាត ប្រជាពលរដ្ឋរស់នៅភូមិស្យាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

[12] សម្ភាសលោក ចុង ម៉ៅ មេទំនប់ រស់នៅភូមិស្យាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។



រូបលេខ២៤ : សកម្មភាពចាប់ត្រីរបស់ក្រុមលោក ចុង ម៉ៅ នៅក្នុងមេទឹកបឹងកក់

ក្រៅពីធានធនត្រីធម្មជាតិដែលប្រមូលបានពីមេទឹកបឹងកក់ នៅមានសត្វស្លាប ល្មូន និងអុសបានមកព្រៃដែលងាប់។ ព្រៃនេះជាទូទៅបានផ្តល់ផលប្រយោជន៍ច្រើន សម្រាប់ប្រជាពលរដ្ឋនៅក្នុងភូមិស្យាអំពិល ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ អ្នកស្រុកអាចទទួលផល ដូចជានៅរដូវប្រាំង អាចកាប់អុសសម្រាប់លក់ផ្គត់ផ្គង់ជីវភាពរបស់ពួកគាត់ និងយកទៅដាំស្ងចម្អិនអាហារ។ សម្រាប់ព្រៃរស់រានគ្គឺឈើទាំងអស់ហ្នឹងមានសត្វ ដូចជាសត្វស្លាបបច្រើនប្រភេទដែរ ពិសេស នៅដើមឆ្នាំក្នុងពេលទឹកនៅពេញមេទឹក មានសត្វស្លាបជាច្រើន។ នៅលើខ្នងទំនប់ ស្ទើរគ្រប់កន្លែងមានសត្វស្លាប។ នៅរដូវទឹកឡើង សត្វស្លាបមកពង នៅចុងឈើ មានដូចជាជត្វកុក ក្រសា រនាល អាអូតមាន់ទឹក និងទាព្រៃ ទាទឹកក៏ច្រើនដែរ។ នៅមានប្រភេទសត្វល្មូន ដូចជាពស់ថ្លាន់ ពស់ថ្លាន់អន្ទេរាង សង់សឿ ពស់ចាន់ល្មម ពស់ព្រលឹត ពស់សម្លាប់កង្កែប និងពស់វែកក៏មានដែរ។

មេទឹកបឹងកក់ក៏ដូចជាមេទឹកផ្សេងៗក្នុងឃុំបារាយណ៍ផ្តល់សក្តានុពលដល់សហគមន៍ឃុំបារាយណ៍ច្រើនវិស័យ ដូចជាត្រីធម្មជាតិដ៏មានឱជារស់ ជម្រកសត្វស្លាប ជម្រកសត្វល្មូន ជាវាលស្រែស្រូវប្រាំងធំល្វឹងល្វើយ ជាទីតាំងអាចចិញ្ចឹមទា គោនិងក្របីរកចំណី ព្រមទាំងជាផ្លូវភ្ជាប់ពីកន្លែងមួយទៅកន្លែងមួយងាយស្រួលប្រជាកសិករធ្វើដំណើរដឹកជញ្ជូនផលិតផលស្រូវផងដែរ។



រូបលេខ២៥ : លោក គង់ សុខមុន្នី និងមន្ត្រីថ្នាក់ឃុំ ព្រមទាំងលោក ចុង ម៉ៅ គឺជាមេទំនប់

ទោះបី ប្រជាកសិករនៅឃុំបារាយណ៍មានមេទឹកសម្រាប់ជួយផ្តល់ទឹកសម្រាប់ធ្វើកសិកម្មក្តី ប៉ុន្តែបច្ចុប្បន្នបរិមាណទឹកមិនមានគ្រប់គ្រាន់សម្រាប់ធ្វើស្រូវ២ដងក្នុង១ឆ្នាំនោះទេ ដោយសារកត្តាធម្មជាតិ និងអាយុកាលរបស់សំណង់ទំនប់ទឹកមានអាយុកាលតាំងពីសម័យបុរាណមក។

## សន្និដ្ឋាន

មេទឹកទាំងអស់ក្នុងឃុំបាពាយណ៍គឺជាសំណង់កសង់ក្នុងសម័យបុរាណ ក៏ប៉ុន្តែអ្នកស្រាវជ្រាវមិនទាន់រកឃើញពីអាយុកាលនៃមេទឹកទាំងអស់នោះទេ។ យ៉ាងណាមិញ ក្រុមស្រាវជ្រាវសហការរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង សាកលវិទ្យាល័យហ្វីនឌ័រ ប្រទេសអូស្ត្រាលី បានសិក្សាធ្វើកំណាយស្រាវជ្រាវនៅលើទំនប់មេទឹកថ្មី ក្នុងភូមិស្បាបឹងវែង នាខែកុម្ភៈ ឆ្នាំ២០២៥។ លទ្ធផលនៃការធ្វើកំណាយស្រាវជ្រាវនឹងបង្ហាញនៅពេលឆាប់ៗខាងមុខ។



រូបលេខ២៦ : រូបភាពធ្វើកំណាយនៅទំនប់មេទឹកថ្មី

សក្តានុពលនៃប្រព័ន្ធធារាសាស្ត្រក្នុងឃុំបាពាយណ៍ពិតជាមានច្រើន និងមានសារប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងឃុំ ព្រមទាំងជាជម្រកសម្រាប់សត្វស្លាប និងរក្សាបរិស្ថានក៏ដូចជាជីវចម្រុះក្នុងតំបន់។

យ៉ាងណាក៏ដោយ កំណើនប្រជាពលរដ្ឋក្នុងឃុំកាន់តែឡើងរហូត ដែលមានតម្រូវការម្ហូបអាហារដើម្បីទ្រទ្រង់ ជម្រុញឱ្យមានផលិតកម្មកាន់តែច្រើន។ ដូច្នេះហើយ ប្រជាពលរដ្ឋបានសំណូមពរឱ្យមានគម្រោងថែរក្សា ឬវិធីយ៉ាងណាមួយធ្វើទំនប់ឱ្យមាំទាំ ហើយឱ្យមានទឹកឱ្យបានច្រើនសម្រាប់ផ្គត់ផ្គង់ ការដាំស្រូវមួយរដូវ អាចធ្វើបានពីរដង។

ម៉្យាងទៀត មេទឹកបឹងកក់ធំមែន ក៏ប៉ុន្តែរាក់ មិនអាចស្តុកទឹកបានច្រើន ដូច្នេះហើយ ប្រជាពលរដ្ឋក៏សំណូមពរឱ្យអាជ្ញាធរឃុំលើកគម្រោងឬស្នើមូលនិធិណាមួយតាមរយៈរដ្ឋក្តី ឯកជនក្តី សហការគ្នាស្តាមេទឹកបឹងកក់ឱ្យជ្រៅ មានប្រភពទឹកអាចគ្រប់គ្រាន់សម្រាប់គ្រប់គ្រងស្រូវប្រាំង[13]។

ទោះបីជាជីកផ្នែកខាងក្នុងឱ្យជ្រៅក្តី បរិមាណទឹកក៏នៅតែមិនគ្រាប់សម្រាប់ប្រជាពលរដ្ឋដែលមានដីក្នុងឃុំបាពាយណ៍ទាំងមូល ដែលតម្រូវមានការទាញទឹកពីប្រភពទឹកធំ ដូចជាទាញទឹកពីបឹងវាម។ ប្រជាពលរដ្ឋក៏សំណូពរថ្នាក់ដឹកនាំភូមិ ឃុំ ស្នើទៅលើមានប្រឡាយជំនួយ ភ្ជាប់ពីបឹងវាម ដែលអាចបូមទឹកបន្ថែមនៅពេលខ្វះទឹក អាចឱ្យប្រជាពលរដ្ឋធ្វើស្រែបាន២ដងក្នុងមួយរដូវ[14]។

---

13 សម្ភាសលោក គង់ សុមុនី ជំទប់ទី១ ឃុំបាពាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

14 សម្ភាសលោក ណោ ណាត ប្រជាពលរដ្ឋរស់នៅភូមិស្បាអំពិលឃុំបាពាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

**ឯកសារពិគ្រោះ**

*-ផុន កសិកា, ឡេង វិទូ, តាកេត ស័កដា, សួ ប៉ុណ្ណារ៉ាត់ «ប្រព័ន្ធជាពសាស្ត្រនៅតំបន់ខាងកើតបន្ទាយលង្វែក ក្នុងឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល»* ក្នុង កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ១(២) ខែវិច្ឆិកា ឆ្នាំ២០២២ ទំព័រ១-២១។

-នាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ វិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ា ដើម្បីសម្បត្តិវប្បធម៌ សាកលវិទ្យាល័យហ្វ៊ីនដឺ «របាយការណ៍បឋម ស្ដីពី គម្រោងស្រាវជ្រាវរាជធានីសម័យកណ្ដាល និង បុរាណដ្ឋាន» ឆ្នាំ២០២៣។

-Nhim, Sotheavin. (2016). Factors that Led to Change of the Khmer Capitals from the 15ht to 17th Century, Sophia University, Tokyo.

*បទសម្ភាសៈ*

*លោក គង់ សុមុនី ជំទប់ទី១ ឃុំបាពយណ៌ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។*

*លោក ចុង ម៉ៅ ប្រជាពលរដ្ឋរស់នៅភូមិស្បាអំពិល ឃុំបាពយណ៌ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។*

*លោក ណោ ណាត ប្រជាពលរដ្ឋរស់នៅភូមិស្បាអំពិល ឃុំបាពយណ៌ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។*